កម្មវិធីកសាងសមត្ថភាពអនាម័យនិងភូតគាមអនាម័យ

# កិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យ (SPS) នៃ អង្គការពាណិជ្ជកម្មពិភពលោក

ហេតុអ្វីបានជាអ្នកចាំបាច់ត្រូវយល់ដឹង ...



Australian Government

Department of Agriculture, Fisheries and Forestry

AusAID

ISBN 0 97516863 0

## ការបដិសេធន៍ទទួលខុសត្រូវ

កូនសៀវភៅស្តីពីកិច្ចព្រមព្រៀងអនាម័យសត្វ និង ភូតគាមអនាម័យ (SPS) នេះ គ្រាន់តែគឺជាការណែនាំឱ្យស្គាល់នូវប្រធានបទនេះប៉ុណ្ណោះ ។ កូនសៀវភៅនេះមានបំណងធ្វើជាមគ្គុទេសក៏សំដៅធ្វើឱ្យមានការយល់ដឹងអំពីបញ្ហាសំខាន់ៗ មួយចំនួនដែលប្រទេសទាំងឡាយគប្បីពិចារណាក្នុងការអនុវត្តកិច្ចព្រមព្រៀង SPS ។ ទោះជាយ៉ាងនេះក្តី ប្រទេសទាំងឡាយគប្បីពិនិត្យមើលប្រភពព័ត៌មានបន្ថែមទៀត មុនពេលធ្វើសេចក្តីសម្រេចចិត្តលើការអនុវត្ត ។ ទោះបីជាមានកិច្ចប្រឹងប្រែងច្រើនដើម្បីធានាឱ្យបាននូវភាពត្រឹមត្រូវនៅក្នុងខ្លឹមសារនៃកូនសៀវភៅនេះក្តី ក៏វាមិនអាចចាត់ទុកជាការបកស្រាយយកជាការបាននៃកិច្ចព្រមព្រៀង SPS ឡើយ ។ គេមិនគប្បីចាត់ទុកកូនសៀវភៅនេះជាការពិពណ៌នាអំពីគោលនយោបាយរបស់រដ្ឋាភិបាលអូស្ត្រាលី ឬ ក៏ជាការតំណាងដោយរដ្ឋាភិបាលអូស្ត្រាលីចំពោះរដ្ឋាភិបាលឬក្រុមដទៃណាមួយឡើយ ។

កូនសៀវភៅពតិមាននេះជាដំបូងត្រូវបានរៀបចំជាភាសាអង់គ្លេសដោយក្រសួងកសិកម្ម នេសាទ និង រុក្ខាប្រមាញ់ នៃរដ្ឋាភិបាលអូស្ត្រាលី និង ត្រូវបានបកប្រែជាភាសាខ្មែរដោយ ណៃ ឈួន ដោយមានជំនួយពីបណ្ឌិត សួន សុធឿន និង លោក ប៊ុនទួន ស៊ីម៉ូណា។

នាយគដ្ឋានកសិកម្ម គង្គា រុក្ខានិងប្រមាញ់ ទទួលស្គាល់ពេញលក្ខណះទៅលើប្រការ ទាំងឡាយដែលទាក់ទងទៅតាមទ្រង់ទ្រាយ នៃអត្ថបទនេះ ។

កូនសៀវភៅនេះបង្ហាញជូនដោយសង្ខេបនូវទស្សនាទាននៃកិច្ចព្រមព្រៀងលើការអនុវត្តវិធានអនាម័យ និងភូតគាមអនាម័យ (ដែលជាទូទៅត្រូវបានហៅថា "កិច្ចព្រមព្រៀង SPS") របស់អង្គការ ពាណិជ្ជកម្មពិភពលោក (WTO) ។ គ្រប់ប្រទេសទាំងអស់ដែលក្លាយជាសមាជិករបស់ WTO ត្រូវអនុវត្តកិច្ចព្រមព្រៀង SPS ។

កូនសៀវភៅនេះបង្ហាញថាហេតុអ្វីបានជាការយល់ដឹងអំពីកិច្ចព្រមព្រៀង SPS មានសារៈសំខាន់សម្រាប់អ្នកទាំងឡាយណាដែលចាប់អារម្មណ៍លើពាណិជ្ជកម្មអន្តរជាតិនៃទំនិញកសិកម្ម ។

កិច្ចព្រមព្រៀង SPS ត្រូវបានបង្ហាញដោយសង្ខេបនៅក្នុងកូនសៀវភៅនេះ ។ ដើម្បីទទួលបាននូវការយល់ដឹងដ៏ពេញលេញមួយអំពីកិច្ចព្រមព្រៀង SPS អ្នកនឹងចាំបាច់ត្រូវរកមើលសៀវភៅបោះពុម្ពផ្សាយ និង ប្រភពព័ត៌មានផ្សេងទៀត ។ យើងផ្តល់ជូនបញ្ជីនៃសៀវភៅបោះពុម្ពផ្សាយ និង ប្រភពព័ត៌មានទាំងនេះនៅចុងបញ្ចប់នៃកូនសៀវភៅនេះ និង យោងដល់ឯកសារទាំងនេះនៅក្នុងអត្ថបទ ដោយប្រើលេខនៅក្នុងវង់ក្រចកជ្រុង [] ។

# សុខភាព និង ពាណិជ្ជកម្មអន្តរជាតិ

ជាគោលការណ៍ កិច្ចព្រមព្រៀង SPS គឺសំដៅលើ*សុខភាព និង ពាណិជ្ជកម្មអន្តរជាតិ* ។ ពាណិជ្ជកម្មអន្តរជាតិ និង ការធ្វើដំណើរបានរីកចម្រើនយ៉ាងខ្លាំងនៅក្នុងអំឡុងពេល ៥០ ឆ្នាំចុងក្រោយនេះ ។ ប្រការនេះបានធ្វើឱ្យមានកំណើនចរាចរផលិតផលដែលអាចធ្វើឱ្យមានហានិភ័យដល់សុខភាព ។ កិច្ចព្រមព្រៀង SPS ទទួលស្គាល់ភាពចាំបាច់ដែលសមាជិក WTO ត្រូវការពារខ្លួនឯងប្រឆាំងនឹងហានិភ័យដែលបណ្តាលមកពីការចូលនៃសមាសភាពចម្រែងនិងជម្ងឺទាំងឡាយ ប៉ុន្តែ ក៏ព្យាយាមកាត់បន្ថយផងដែរនូវផលប៉ះពាល់អវិជ្ជមាននៃវិធាន SPS លើពាណិជ្ជកម្ម ។

ជារួម ផ្នែក *សុខភាព* នៃកិច្ចព្រមព្រៀង SPS មានន័យថាសមាជិក WTO អាចការពារជីវិត ឬសុខភាពមនុស្ស សត្វ ឬ រុក្ខជាតិ ដោយអនុវត្តវិធានការគ្រប់គ្រងហានិភ័យដែលពាក់ព័ន្ធនឹងការនាំចូល ។ ជាទូទៅ វិធានការទាំងនោះមានទម្រង់ជាចត្តាឡីស័ក ឬ លក្ខខណ្ឌសុវត្ថិភាពអាហារ ។

វិធានការដែលសមាជិក WTO អនុវត្តអាចត្រូវធ្វើចំណាត់ថ្នាក់ជាវិធានអនាម័យ (ទាក់ទងនឹងជីវិតឬសុខភាពមនុស្សឬសត្វ) ឬ ភូតគាមអនាម័យ (ទាក់ទងនឹងជីវិតឬសុខភាពរុក្ខជាតិ) ។ ជាទូទៅ វិធានការទាំងនេះត្រូវតែស្គាល់ជាវិធាន SPS ។

ជារួម ផ្នែក *ពាណិជ្ជកម្មអន្តរជាតិ* នៃកិច្ចព្រមព្រៀង SPS មានន័យថា ក្នុងការព្យាយាមការពារសុខភាព សមាជិក WTO មិនត្រូវប្រើវិធាន SPS ដែលៈ មិនចាំបាច់ គ្មានមូលដ្ឋានវិទ្យាសាស្ត្រ មានលក្ខណៈតាមអំពើចិត្ត ឬ ដែលគឺជាការបន្លំដាក់កំហិតលើពាណិជ្ជកម្មអន្តរជាតិ ។

កូនសៀវភៅនេះផ្តោតលើពាណិជ្ជកម្មនៃទំនិញកសិកម្ម ជាពិសេស លើបញ្ហាសុខភាពសត្វនិងរុក្ខជាតិ ។ វាលើកឡើងតែបន្តិចបន្តួចប៉ុណ្ណោះនូវបញ្ហាសុខភាពមនុស្ស ។

# តើកិច្ចព្រមព្រៀង SPS និយាយពីអ្វីខ្លះ?

កិច្ចព្រមព្រៀង SPS មាន ១៤ មាត្រា ដែលរួមមានសិទ្ធិនិងកាតព្វកិច្ចដែលសមាជិក WTO បានឯកភាព។ កិច្ចព្រមព្រៀង SPS ក៏មានផងដែរនូវឧបសម្ព័ន្ធចំនួនបីដែលផ្តល់និយមន័យនៃពាក្យផ្សេងៗ និង ពន្យល់ពីកាតព្វកិច្ចមួយចំនួននៅក្នុងកិច្ចព្រមព្រៀង SPS ។

ពាក្យតទៅនេះត្រូវបានលើកឡើងនៅក្នុងកូនសៀវភៅនេះ: សុខុដុមនីយកម្ម សមមូលភាព កម្រិតសមស្របនៃការការពារ ការវាយតម្លៃហានិភ័យ ស្ថានភាពភូមិសាស្ត្រតំបន់ និង តម្លាភាព។ ពាក្យទាំងនេះតំណាងឱ្យគោលការណ៏គន្លឹះមួយចំនួននៅក្នុងកិច្ចព្រមព្រៀង SPS ។

យើងមិនបរិយាយលម្អិតនូវបទប្បញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀង SPS នៅក្នុងកូនសៀវភៅនេះទេ។ អ្នកអាចអានអត្ថបទទាំងស្រុងនៃកិច្ចព្រមព្រៀង SPS [១] នៅក្នុងគេហទំព័រ WTO ។ គេហទំព័រនេះក៏មានចុះផ្សាយផងដែរនូវការបោះពុម្ពផ្សាយ WTO [២] ដែលពន្យល់កាន់តែពេញលេញនូវកិច្ចព្រមព្រៀង SPS រួមមានភាពខុសគ្នារវាងវិធាន SPS និង របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម។ អ្នកអាចទទួលបានព័ត៌មានពិស្តារបន្ថែមទៀត និង យល់ដឹងអំពីវឌ្ឍនភាពបច្ចុប្បន្ន ដោយអាន "ផ្លូវចូល" ('gateway') ទៅកាន់វិធាន SPS [៣] នៅក្នុងគេហទំព័រ WTO ។




កំណើនបរិមាណនៃពាណិជ្ជកម្មអន្តរជាតិ មានន័យថានីតិវិធីចត្តាឡីស័កត្រូវតែអាចឆ្លើយតបទៅនឹងទំនិញ និង ការវេចខ្ចប់ប្រភេទខុសៗគ្នាជាច្រើន ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដ៏ស្មុគ្រស្មាញ និង ច្រកចូលសម្រាប់សត្វល្អិតចង្រៃនិងជម្ងឺ។

សិទ្ធិនិងកាតព្វកិច្ចជាមូលដ្ឋានរបស់សមាជិក WTO មានចែងនៅក្នុងមាត្រា ២ នៃកិច្ចព្រមព្រៀង SPS ដែលអត្ថបទនៃមាត្រានេះត្រូវបានផ្តល់ជូននៅក្នុងប្រអប់ខាងក្រោមនេះ ។ នៅក្នុងចំណុចផ្សេងៗនៃកូនសៀវភៅនេះ យើងនឹងនិយាយយោងដល់មាត្រាផ្សេងទៀតពាក់ព័ន្ធនឹងប្រធានបទខ្លះៗដែលត្រូវបានពិភាក្សា ។

# តើអ្នកណាគ្រប់គ្រងកិច្ចព្រមព្រៀង SPS?

កិច្ចព្រមព្រៀង SPS ត្រូវគ្រប់គ្រងដោយគណៈកម្មាធិការស្តីពីវិធានអនាម័យនិងភូតគាមអនាម័យ (“គណៈកម្មាធិការ SPS”) ដែលនៅក្នុងនោះសមាជិក WTO អាចចូលរួម ។ គណៈកម្មាធិការ SPS គឺជាវេទិការសម្រាប់ការពិគ្រោះយោបល់ ដែលនៅក្នុងនោះ សមាជិក WTO ជួបប្រជុំគ្នាយ៉ាងទៀងទាត់ ដើម្បីពិភាក្សាវិធាន SPS និង ផលប៉ះពាល់របស់វាលើពាណិជ្ជកម្ម ដើម្បីត្រួតពិនិត្យការអនុវត្ត កិច្ចព្រមព្រៀង SPS និង ដើម្បីខិតខំជៀសវាងវិវាទដែលអាចកើតឡើង ។

## កិច្ចព្រមព្រៀង SPS មាត្រា ២_សិទ្ធិ និង កាតព្វកិច្ចជាមូលដ្ឋាន

១. សមាជិកទាំងឡាយមានសិទ្ធិចាត់វិធានអនាម័យនិងភូតគាមអនាម័យ ដែលចាំបាច់ដើម្បីការពារជីវិត ឬសុខភាពមនុស្ស សត្វ ឬ រុក្ខជាតិ ប្រសិនបើវិធានបែបនេះមិនផ្ទុយគ្នានឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះទេ។

២. សមាជិកទាំងឡាយត្រូវធានាឱ្យបានថាវិធានអនាម័យនិងភូតគាមអនាម័យត្រូវអនុវត្តត្រឹមតែក្នុងកម្រិត មួយដែលចាំបាច់ដើម្បីការពារជីវិតឬសុខភាពមនុស្ស សត្វ ឬ រុក្ខជាតិតែប៉ុណ្ណោះ ដោយផ្អែកលើគោលការណ៍វិទ្យាសាស្ត្រ និង មិនត្រូវបានរក្សាទុកដោយគ្មានភស្តុតាងវិទ្យាសាស្ត្រគ្រប់គ្រាន់ឡើយ លើកលែងតែករណីដូចមានចែងក្នុងកថាខណ្ឌ ៧ នៃ មាត្រា ៥។

៣. សមាជិកទាំងឡាយត្រូវធានាឱ្យបានថាវិធានអនាម័យនិងភូតគាមអនាម័យរបស់ខ្លួនមិនរើសអើងតាម ទំនើងចិត្តឬដោយគ្មានហេតុផលរវាងសមាជិកដែលមានលក្ខខណ្ឌដូចគ្នាសុទ្ធសាធឬស្រដៀងគ្នា ដោយរួម ទាំងការអនុវត្តនៅក្នុងទឹកដីរបស់ខ្លួន និង ទឹកដីនៃប្រទេសជាសមាជិកផ្សេងទៀត ។ វិធានអនាម័យនិង ភូតគាមអនាម័យមិនត្រូវអនុវត្តតាមវិធីមួយដែលគឺជាការបន្លំដាក់កំហិតលើពាណិជ្ជកម្មអន្តរជាតិឡើយ ។

៤. វិធានអនាម័យនិងភូតគាមអនាម័យដែលមានស្របគ្នាជាមួយនឹងបទប្បញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀងនេះ នឹងត្រូវបានសន្មតថាអនុលោមតាមកាតព្វកិច្ចរបស់សមាជិកតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងទូទៅលើតារាង ពន្ធគយនិងពាណិជ្ជកម្ម (GATT) ឆ្នាំ ១៩៩៤ ដែលចែងពីការប្រើ វិធានអនាម័យនិងភូតគាមអនាម័យ ជាពិសេស បទប្បញ្ញត្តិនៃមាត្រា XX(b) ។

សមាជិក WTO ទទួលផលប្រយោជន៍ពីការចូលរួមដ៏សកម្មនៅក្នុងគណៈកម្មាធិការ SPS ។ គណៈកម្មាធិការ SPS មានសកម្មភាពផ្សេងៗដើម្បីជួយសមាជិកក្នុងការអនុវត្តកិច្ចព្រមព្រៀង SPS ។ អ្នកអាចរកបានព័ត៌មានបន្ថែមទៀតអំពីគណៈកម្មាធិការ SPS [៤] នៅក្នុងគេហទំព័រ WTO ។

# ហានិភ័យ និង ទំនិញ

ជារួម កិច្ចព្រមព្រៀង SPS ត្រូវអនុវត្តលើវិធានទាំងឡាយដែលត្រូវបានអនុវត្តដោយសមាជិក WTO ដើម្បីការពារជីវិតឬសុខភាពមនុស្ស សត្វ ឬ រុក្ខជាតិ នៅក្នុងដែនដីរបស់ខ្លួន ទល់នឹងហានិភ័យមួយចំនួន និង ដែលអាចមានផលប៉ះពាល់លើពាណិជ្ជកម្មអន្តរជាតិ ។

ហានិភ័យចំពោះជីវិតឬសុខភាពសត្វ ចេញមកពីៈ

- ការចូល ការករកើតឬការរាលដាលសត្វល្អិត (រួមទាំងរុក្ខជាតិតូចៗ) ជម្ងឺដែលបង្ករឡើង ភ្នាក់ងារចម្លងរោគ ឬ
- សារធាតុបន្ថែម សារធាតុបំពុល (រួមទាំងថ្នាំសម្លាប់សត្វល្អិត និង សំណល់ថ្នាំសត្វ និង សារធាតុបន្ថែមក្រៅផ្សេងៗទៀត) ជាតិពុល ឬ សរីរៈចម្លងរោគនៅក្នុងចំណីអាហារ ។

ហានិភ័យចំពោះជីវិតឬសុខភាពរុក្ខជាតិ ចេញមកពីៈ

- ការចូល ការករកើត ឬ ការរាលដាលសត្វល្អិត (រួមទាំងរុក្ខជាតិតូចៗ) ជម្ងឺ សរីរៈចម្លងរោគ ឬ សរីរៈនាំឱ្យមានជម្ងឺ ។

ហានិភ័យចំពោះជីវិតឬសុខភាពមនុស្សចេញមកពីសារធាតុបន្ថែម សារធាតុបំពុល ឬ សរីរៈនាំឱ្យមានជម្ងឺនៅក្នុងចំណីអាហារ ឬ ភេសជ្ជៈ ជម្ងឺដែលចម្លងដោយសត្វ រុក្ខជាតិ ឬ ផលិតផលរបស់វា ឬ ការចូល ការករកើត ឬ ការរាលដាលសរីរៈចង្រៃ ។

ហេតុនេះ ការនាំចូលចំណីអាហារ រុក្ខជាតិ (រួមទាំងផលិតផលរុក្ខជាតិ) និង សត្វ (រួមទាំងផលិតផលសត្វ) គឺជាច្រកចូលមានហានិភ័យដ៏សំខាន់ទាំងបី ប៉ុន្តែ ហានិភ័យមិនមែនមានតែលើចំណីអាហារ និង ទំនិញកសិកម្មប៉ុណ្ណោះទេ ។

**សំណួរអ្នកនាំចេញ ▼**

**យើងនាំចេញគ្រឿងម៉ាស៊ីន មិនមែនទំនិញកសិកម្មទេ ។ ហេតុអ្វីបានជាយើងចាំបាច់ត្រូវយល់ដឹងអំពី កិច្ចព្រមព្រៀង SPS និង វិធាន SPS?**

ថ្វីបើការនាំចេញរបស់អ្នក អាចមិនមានហានិភ័យពិតមែនក្តី ក៏វាអាចមានជាប់សំណល់ដីឬរុក្ខជាតិ ឬ អាចត្រូវបាន ដឹកជញ្ជូនដោយប្រើសម្ភារៈវេចខ្ចប់ទាំងឡាយ ដូចជាក្តារ ឬ ចំបើងរោងចក្រ ជាដើម ។ ហេតុនេះ វិធាន SPS គឺ ពាក់ព័ន្ធនឹងអ្នកនាំចេញ និង អ្នកនាំចូលទាំងអស់ ។

# ធនធានចាំបាច់ដើម្បីអនុវត្តកិច្ចព្រមព្រៀង SPS

ជាទូទៅ ការទទួលខុសត្រូវលើការអនុវត្តកិច្ចព្រមព្រៀង SPS គឺជាបន្ទុករបស់ក្រសួងរដ្ឋាភិបាល និង កន្លែងទុកដាក់ថ្នាក់ជាតិដែលមានជំនាញនិងព័ត៌មានពាក់ព័ន្ធនឹងសុខភាពរុក្ខជាតិនិងសត្វ ក៏ដូចជា សុវត្ថិភាពចំណីអាហារផងដែរ ។ ជាធម្មតា ស្ថាប័នអនុវត្តរួមមានអង្គការជាតិការពាររុក្ខជាតិ (NPPO) និង អាជ្ញាធរស្មើគ្នាដែលទទួលបន្ទុកសុខភាពសត្វនិងសុវត្ថិភាពអាហារ ។



ការប្រមូលសំណាកសរីរៈចង្រៃនិងជម្ងឺ គឺជាឧបករណ៍ដ៏សំខាន់ក្នុងការកំណត់និងបង្ហាញស្ថានភាព សុខភាពរុក្ខជាតិ ។

គេចាំបាច់ត្រូវមានក្របខណ្ឌនិយ័តកម្មក្នុងស្រុក ដែលរាប់បញ្ចូលការងារ ការទទួលខុសត្រូវ និង អំណាចរបស់ស្ថាប័ន រួមជាមួយនឹងប្រព័ន្ធបង្ខំឱ្យមានអនុលោមភាព ។ ប្រការនេះលើកទឹកចិត្តដល់ទំនុកចិត្តលើការវាយតម្លៃ និង ទំនុកចិត្តលើវិញ្ញាបនប័ត្រដែលបានចេញ ទាក់ទិននឹងវិធាន SPS ។

ការកំណត់ស្ថានភាពសុខភាពសត្វឬរុក្ខជាតិ និង ការរៀបចំវិធាន SPS សមស្រប រួមមានការប្រមូលព័ត៌មានផ្សេងៗជាច្រើនពីប្រភពខុសៗគ្នាជាច្រើន ។ ព័ត៌មាននេះគឺមានតម្លៃជានិច្ច ហើយវាគឺជាប្រការសំខាន់ដែលព័ត៌មាននេះត្រូវបានគេរៀបចំធ្វើចំណាត់ថ្នាក់តាមប្រភេទ និង ទុកដាក់ដើម្បីឱ្យមានលក្ខណៈងាយស្រួលក្នុងការរក ។

ដើម្បីកំណត់ហានិភ័យ និង ដើម្បីធ្វើការស្រាវជ្រាវ អភិវឌ្ឍ និង អនុវត្តវិធាន SPS ផ្អែកលើវិទ្យាសាស្ត្រ សមាជិក WTO ចាំបាច់ត្រូវមានបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលលើមុខជំនាញសមស្រប ។

ការមានជំនាញលើការរកឱ្យឃើញ និង ការធ្វើរោគវិនិច្ឆ័យសរីរៈចង្រៃនិងជម្ងឺនៃសត្វនិងរុក្ខជាតិគឺចាំបាច់ ដើម្បីគាំទ្រពាណិជ្ជកម្មនៃទំនិញកសិកម្ម រួមទាំងជំនាញខាងបាណកសត្វ រោគសាស្ត្ររុក្ខជាតិ រោគសាស្ត្រ បុសុពេទ្យ ការសិក្សារោគរាតត្បាត និង វិទ្យាសាស្ត្រធ្វើចំណាត់ប្រភេទ ។ មន្ត្រីចត្តាឡីស័ក និង មន្ត្រីអធិការកិច្ចដែលបានទទួលការបណ្តុះបណ្តាលលើបច្ចេកទេសជ្រើសរើសសំណាកនិងបច្ចេកទេសរកឱ្យឃើញ គឺចាំបាច់ត្រូវមាននៅតាមគ្រប់ច្រកនាំចូល និង ច្រកនាំចេញ ។

ការយកសំណាកសារធាតុពិនិត្យពីសត្វនិងរុក្ខជាតិ និង មន្ទីរពិសោធន៍ដែលមានសម្ភារៈបរិក្ខារ សម្រាប់ធ្វើរោគវិនិច្ឆ័យ គឺមានសារៈសំខាន់បំផុត ។

ចំណោទទូទៅ ▼

**ការអនុវត្តកិច្ចព្រមព្រៀង SPS នៅក្នុងប្រទេសយើងខ្ញុំនឹងតម្រូវឱ្យយើងខ្ញុំចំណាយច្រើន ហើយធនធានរបស់ យើងខ្ញុំគឺនៅក្រខ្សត់នៅឡើយ ។ តើវាគឺជាប្រការមានប្រយោជន៍ឬទេ?**

ការសិក្សាថ្មីៗមួយដោយធនាគារពិភពលោក [៥] បានរកឃើញថាចំណាយនៃការគោរពតាមស្តង់ដារចំណីអាហារ អន្តរជាតិ ប្រហែលជាមានចំនួនតិចជាងការរំពឹង និង ថាអត្ថប្រយោជន៍អាចត្រូវគេវាយតម្លៃទាប ដោយសារ វាពិបាកវាស់ជាងចំណាយ ។ របាយការណ៍នេះក៏បានកត់សម្គាល់ផងដែរថាប្រទេសកំពុងអភិវឌ្ឍទាំងឡាយដែល បានអនុម័តយកស្តង់ដារអន្តរជាតិ បានរក្សាទុកឬបង្កើនលទ្ធភាពចូលទីផ្សាររបស់ខ្លួនសម្រាប់ទំនិញកសិកម្ម និង ស្ថិតនៅក្នុងស្ថានភាពល្អមួយដើម្បីបន្តដំណើរការនេះ ។ អ្នកឯកទេសជំនួយបច្ចេកទេសមួយរូបដែលថ្លែងទៅកាន់ សិក្ខាសាលា WTO មួយថ្មីៗនេះ (ព័ត៌មានពិស្តារមាន នៅក្នុង [៣]) បានគូសបង្ហាញថា ជួនកាល ប្រទេសទាំងឡាយវាយតម្លៃទាបចំពោះធនធានដែលគេមានដើម្បីអនុវត្តកិច្ចព្រមព្រៀង SPS ។ ឧទាហរណ៍ ប្រទេសទាំងនេះអាចមានអ្នកមានជំនាញដែលគេត្រូវការ ប៉ុន្តែ គេចាំបាច់ត្រូវប្រមូលផ្តុំអ្នកទាំងនេះដាក់ក្នុងស្ថាប័នមួយ ។

# គោលការណ៍ចម្បងនៃកិច្ចព្រមព្រៀង SPS

គោលការណ៍ចម្បងនៃសុខដុមនីយកម្ម សមមូល កម្រិតសមស្របនៃការការពារ (ALOP) ការវាយតម្លៃហានិភ័យស្ថានភាពតំបន់ និង តម្លាភាព ត្រូវបានដាក់បញ្ចូលក្នុងមាត្រាជាក់លាក់នៃកិច្ចព្រមព្រៀង SPS ។

## សុខដុមនីយកម្ម[១]

សមាជិក WTO មានសិទ្ធិសម្រេចវិធាន SPS របស់ខ្លួនផ្ទាល់ ប្រសិនបើវិធានទាំងនោះគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង SPS ។ ប៉ុន្តែ ក្រោមគោលការណ៍សុខដុមនីយកម្ម សមាជិក WTO ទាំងអស់ ត្រូវបានលើកទឹកចិត្តឱ្យប្រកាន់យកវិធាន SPS របស់ខ្លួនផ្អែកលើស្តង់ដារ ការណែនាំ និង អនុសាសន៍អន្តរជាតិដែលបានអនុម័តរួច ។ គណៈកម្មាធិការ SPS ជម្រុញនិងឃ្លាំមើលសុខដុមនីយកម្មអន្តរជាតិ ។

មានស្ថាប័នកំណត់ស្តង់ដារអន្តរជាតិចំនួនបី ដែលត្រូវបានចែងយ៉ាងជាក់លាក់នៅក្នុងកិច្ចព្រមព្រៀង SPS ។ ស្ថាប័នទាំងនេះច្រើនត្រូវបានគេហៅថា "បងប្អូនស្រីបីនាក់" (សូមមើលប្រអប់នៅដើមទំព័របន្ទាប់)៖

- អនុសញ្ញាអន្តរជាតិស្តីពីការការពាររុក្ខជាតិ (IPPC) ដែលទទួលកិច្ចការខាងសុខភាពរុក្ខជាតិ ។
- អង្គការសុខភាពសត្វពិភពលោក (OIE) ដែលទទួលកិច្ចការខាងសុខភាពសត្វ ។
- គណៈកម្មការ Codex Alimentarius ដែលទទួលកិច្ចការខាងសុវត្ថិភាពអាហារ ។

សមាជិក WTO ទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យចូលរួមយ៉ាងសកម្មនៅក្នុងស្ថាប័នបងប្អូនស្រីទាំងបីនេះដែលផ្តល់វេទិការផ្សេងទៀតសម្រាប់ការផ្តល់ជំនួយបច្ចេកទេស ។

**តើសមាជិកអាចទទួលជំនួយក្នុងការបណ្តុះបណ្តាលបុគ្គលិកដែលពួកគេត្រូវការដើម្បីអាចបំពេញកាតព្វកិច្ចរបស់ ខ្លួនតាមកិច្ចព្រមព្រៀង SPS ឬទេ?**

ជាផ្នែកមួយនៃកិច្ចព្រមព្រៀង SPS សមាជិក WTO ត្រូវបានលើកទឹកចិត្តឱ្យផ្តល់ជំនួយបច្ចេកទេសដល់សមាជិក WTO ទាំងឡាយដែលជាប្រទេសកំពុងអភិវឌ្ឍ ។ ឧទាហរណ៍ រដ្ឋាភិបាលអូស្ត្រាលី តាមរយៈអង្គការ AusAID និង ក្រសួងកសិកម្ម នេសាទ និង រុក្ខាប្រមាញ់ កំពុងដំណើរការកម្មវិធីកសាងសមត្ថភាព SPS ដោយយកចិត្តទុកដាក់លើបណ្តាប្រទេសអាស៊ាន ។

ព័ត៌មានបន្ថែម ▼

[១] មាត្រា ៣ នៃកិច្ចព្រមព្រៀង SPS

## សមមូល[២]

កិច្ចព្រមព្រៀង SPS តម្រូវឱ្យសមាជិក WTO ដែលធ្វើការនាំចូល ទទួលយកវិធាន SPS របស់សមាជិក WTO ដែលធ្វើការនាំចេញ ជាសមមូល ប្រសិនបើប្រទេសនាំចេញបង្ហាញដោយគ្មានលំអៀងដល់ប្រទេសនាំចូល ថាវិធានរបស់ខ្លួនសម្រេចបាននូវ ALOP របស់ប្រទេសនាំចូល ។ ជាធម្មតា ការទទួលស្គាល់សមមូល ត្រូវសម្រេចបានតាមរយៈការពិគ្រោះយោបល់ទ្វេភាគី និង ការផ្លាស់ប្តូរព័ត៌មានបច្ចេកទេសគ្នា ។

### បងប្អូនស្រីទាំងបី - កំណត់ស្តង់ដារអន្តរជាតិសម្រាប់វិធាន SPS

#### អនុសញ្ញាអន្តរជាតិស្តីពីការការពាររុក្ខជាតិ

អនុសញ្ញាអន្តរជាតិស្តីពីការការពាររុក្ខជាតិ (IPPC) គឺជាសន្ធិសញ្ញាដែលត្រូវប្រតិបត្តិស្របតាមផ្លូវច្បាប់ស្តីពីសុខភាពរុក្ខជាតិដែលគ្រប់គ្រងដោយអង្គការស្បៀងអាហារនិងកសិកម្ម (FAO) ប៉ុន្តែ ត្រូវបានអនុវត្តតាមរយៈកិច្ចសហប្រតិបត្តិការរបស់រដ្ឋាភិបាលជាសមាជិក និង អង្គការការពាររុក្ខជាតិប្រចាំតំបន់ ។

គោលបំណងរបស់ IPPC គឺដើម្បីសម្របសម្រួលការងារដើម្បីទប់ស្កាត់ការរីករាលដាលនិងការនាំចូលដោយមក ជាមួយនូវសរីរៈចង្រៃលើរុក្ខជាតិ និង ផលិតផលរុក្ខជាតិ និង ដើម្បីជម្រុញវិធានសមស្របដើម្បីគ្រប់គ្រងសរីរៈ ចង្រៃលើរុក្ខជាតិ និង ផលិតផលរុក្ខជាតិទាំងនេះ ដោយមានការរំខានអប្បបរមាចំពោះពាណិជ្ជកម្ម ។

IPPC អភិវឌ្ឍស្តង់ដារអន្តរជាតិសម្រាប់វិធានភូតគាមអនាម័យ (ISPMs) ។ ISPMs លើសពី ២៥ ត្រូវបាន បោះពុម្ពផ្សាយមកដល់ពេលនេះ រួមមានៈ ISPM ១ ដែលលើកឡើងពីគោលការណ៍ទាំងឡាយដើម្បីការការពាររុក្ខជាតិ និង ការអនុវត្តវិធានភូតគាមអនាម័យនៅក្នុងពាណិជ្ជកម្មអន្តរជាតិ និង ISPM ៥ ដែលគឺជា សទ្ទានុក្រមមួយនៃពាក្យបច្ចេកទេសភូតគាមអនាម័យ ។ បញ្ជីពេញលេញមួយនៃ ISPM គឺមាននៅក្នុងគេហទំព័រភូតគាមអនាម័យអន្តរជាតិ [៦] ដែលគឺជាវេទិកាមួយសម្រាប់រាយការណ៍ និង ផ្លាស់ប្តូរព័ត៌មានគ្នាដោយរដ្ឋាភិបាលទាំងឡាយ ។

#### អង្គការសុខភាពសត្វពិភពលោក

អង្គការសុខភាពសត្វពិភពលោក (OIE) [៧] ត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងអន្តរជាតិមួយកាលពី ឆ្នាំ ១៩២៤ ដោយមានប្រទេសជាសមាជិកចំនួន ២៨ ។ មកដល់ពេលនេះ អង្គការនេះបានពង្រីកឡើងដល់ប្រទេសជាសមាជិកចំនួន ១៦៧ ។

---

[២] មាត្រា ៤

គោលបំណងរបស់អង្គការនេះរួមមានការធានាឱ្យបាននូវតម្លាភាពនៅក្នុងស្ថានភាពជម្ងឺសត្វ និងរោគឆ្លងពីសត្វពិភពលោក ការបោះពុម្ពផ្សាយស្តង់ដារសុខាភិបាលសម្រាប់ការធ្វើពាណិជ្ជកម្មសត្វ និង ផលិតផលសត្វ ការជម្រុញបបង្កើនជំនាញបសុពេទ្យ កែលំអសុវត្ថិភាពនៃចំណីអាហារដែលមានប្រភពពីសត្វ និង ការជម្រុញ សុខុមាលភាពសត្វតាមរយៈអភិក្រមផ្អែកលើវិទ្យាសាស្ត្រ ។

ស្តង់ដារ ការណែនាំ និង អនុសាសន៍របស់ OIE មាននៅក្នុងក្រមសុខភាពសត្វរស់លើដីគោក (Terrestrial Animal Health Code) សៀវភៅណែនាំអំពីការធ្វើតេស្តរោគវិនិច្ឆ័យ និងវ៉ាក់សាំងសម្រាប់សត្វរស់លើដី គោក (Manual of Diagnostic Tests and Vaccines for Terrestrial Animals) ក្រមសុខភាពសត្វ រស់នៅក្នុងទឹក (Aquatic Animal Health Code) និង សៀវភៅណែនាំអំពីការធ្វើតេស្តរោគវិនិច្ឆ័យ សម្រាប់សត្វរស់នៅក្នុងទឹក (the Manual of Diagnostic Tests for Aquatic Animals) ។

**គណៈកម្មាធិការក្បួនច្បាប់ចំណើអាហារ Codex Alimentarius**

គណៈកម្មាធិការ Codex Alimentarius ("ក្រមចំណីអាហារ") គឺជាស្ថាប័នមួយនៃកម្មវិធីស្តង់ដារចំណី អាហាររួមរបស់អង្គការស្បៀងអាហារនិងកសិកម្ម (FAO) និង អង្គការសុខភាពពិភពលោក (WHO) ។

ក្បួនច្បាប់ [៨] អភិវឌ្ឍ និង លើកទឹកចិត្តការអនុវត្តស្តង់ដារ ក្រមអនុវត្តន៍ ការណែនាំ និង អនុសាសន៍ដែល រួមមានគ្រប់ទិដ្ឋភាពទាំងអស់នៃសុវត្ថិភាពចំណីអាហារ រួមទាំងការចាត់ចែងនិងការចែកចាយ ។ ក្នុងការកំណត់ ស្តង់ដារអន្តរជាតិសម្រាប់ចំណីអាហារ Codex មានកាតព្វកិច្ចទ្វេដើម្បីការពារសុខភាពរបស់អ្នកប្រើប្រាស់ និង ដើម្បីធានាឱ្យបាននូវការអនុវត្តប្រកបដោយឧយុត្តិធម៌នៅក្នុងពាណិជ្ជកម្មចំណីអាហារ ។

គណៈកម្មាធិការ Codex Alimentarius បានអភិវឌ្ឍអត្ថបទជាក់លាក់ជាច្រើនដែលដាក់បញ្ចូលទិដ្ឋភាព ផ្សេងៗនៃសុវតិភាពនិងគុណភាពចំណីអាហារ ដែលមានបង្ហាញជូននៅក្នុងគេហទំព័រ Codex [៨] ។

សំណួរនិងចម្លើយ ▼

**ខ្ញុំគឺជាអ្នកនាំចេញផលិតផលកសិកម្ម ។ តើខ្ញុំត្រូវធ្វើដូចម្តេចទើបអាចដឹងច្បាស់ថាវិធាន SPS ដែលខ្ញុំអនុវត្ត លើផលិតផលរបស់ខ្ញុំ នឹងឆ្លើយតបទៅនឹងលក្ខខណ្ឌរបស់ប្រទេសនាំចូល?**

វាគឺជាប្រការសំខាន់ដែលត្រូវពិគ្រោះជាមួយអាជ្ញាធរពាក់ព័ន្ធនៃប្រទេសនាំចូល ។ អាជ្ញាធរទាំងនេះអាចផ្តល់ ព័ត៌មានអំពីលក្ខខណ្ឌចត្តាឡីស័ករបស់ខ្លួនចំពោះការនាំចូលផលិតផលកសិកម្ម ។ ការឆ្លើយតបទៅនឹងស្តង់ដារ អន្តរជាតិពាក់ព័ន្ធរបស់បងប្អូនស្រីទាំងបី គឺជាចំណុចចាប់ផ្តើមមួយដ៏ល្អ ។

# កម្រិតសមស្របនៃការការពារ[៣]

យោងទៅតាមកិច្ចព្រមព្រៀង SPS កម្រិតសមស្របនៃការការពារ (ALOP) គឺជាកម្រិតនៃការការពារដែល ត្រូវបានចាត់ទុកថាសមស្របដោយប្រទេសជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) ដើម្បីការពារជីវិត ឬសុខភាពរបស់មនុស្ស សត្វ និងរុក្ខជាតិ នៅក្នុងដែនដីរបស់គេ ។

ការបែងចែករវាង ALOP ដែលបង្កើតឡើងដោយសមាជិកមួយនៃអង្គការ WTO និង វិធាន SPS គឺមានសារៈសំខាន់ ។ ALOP គឺជាគោលបំណងទូលំទូលាយមួយ ។ វិធាន SPS ត្រូវបានបង្កើតឡើង ដើម្បីសម្រេចឱ្យបាននូវគោលបំណងនោះ ។ បើគិតតាមលំដាប់ ការកំណត់ ALOP មានមុនការបង្កើត វិធាន SPS ។

សមាជិកនីមួយៗនៃអង្គការ WTO មានសិទ្ធិក្នុងការកំណត់ ALOP របស់គេ ។ ក៏ប៉ុន្តែក្នុងការកំណត់ ALOP របស់គេ សមាជិកនៃអង្គការ WTO គួរតែគិតគូរទៅលើគោលបំណង ដែលកាត់បន្ថយការប៉ះពាល់ជាអវិជ្ជមានទៅលើការធ្វើពាណិជ្ជកម្ម ។ លើសពីនេះទៀត សមាជិកនៃអង្គការ WTO ត្រូវបានតម្រូវឱ្យអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវទស្សនាទាន ALOP ពោលគឺ គេត្រូវតែ "ជៀសវាងការរើសអើងដោយរំលោភ ឬ ដោយគ្មានហេតុផល " ដែល "ធ្វើឱ្យមានការរើសអើង ឬក៏ការរឹតត្បិតដោយភាពលាក់បាំងលើការធ្វើពាណិជ្ជកម្មជាអន្តរជាតិ" ។



បង្កើនសមត្ថភាពក្នុងការអនុវត្តវិធាន SPS អាចផ្តល់ផលប្រយោជន៍ដល់របរកសិកម្មក្នុងស្រុកផងដែរ ។

---

[៣] មាត្រា ៥

## ការវាយតម្លៃហានិភ័យ[៣]

កិច្ចព្រមព្រៀង SPS តម្រូវឱ្យសមាជិកអង្គការ WTO យកការវាយតម្លៃហានិភ័យធ្វើជាមូលដ្ឋានសម្រាប់វិធាន SPS ឱ្យបានសមស្របទៅតាមកាលៈទេសៈ ។ នៅពេលធ្វើការវាយតម្លៃហានិភ័យបែបនេះ សមាជិកអង្គការ WTO ត្រូវបានតម្រូវឱ្យគិតគូរលើបច្ចេកទេសវាយតម្លៃហានិភ័យដែលបង្កើតឡើងដោយអង្គការអន្តរជាតិដែលពាក់ព័ន្ធនានា ។

មូលហេតុដែលសមាជិកអង្គការ WTO ធ្វើការវាយតម្លៃហានិភ័យ គឺដើម្បីធ្វើការកំណត់វិធាន SPS ដែលអនុវត្តសម្រាប់ទំនិញនាំចូល ដើម្បីសម្រេចឱ្យបានកម្រិតសមស្របនៃការការពារ ALOP របស់គេ ។ ក៏ប៉ុន្តែវិធាន SPS ដែលប្រទេសជាសមាជិកអង្គការ WTO មួយយល់ព្រមអនុវត្តមិនត្រូវមានលក្ខណៈរឹតត្បិតការធ្វើពាណិជ្ជកម្មឱ្យហួសពីភាពចាំបាច់ដើម្បីសម្រេចបាននូវ ALOP របស់គេនោះឡើយ ពោលគឺ ត្រូវគិតគូរពីភាពអាចធ្វើបានតាមលក្ខណៈបច្ចេកទេស និង សេដ្ឋកិច្ច ។

**និយមន័យនៃពាក្យការវាយតម្លៃហានិភ័យ ត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យថា:**

- ជាការវាយតម្លៃនៃភវនីយភាព (likelihood) នៃការចូល ការបង្កើត ឬការរាលដាលរបស់សរីរៈចង្រៃ ឬជម្ងឺ នៅក្នុងដែនដីនៃប្រទេសជាសមាជិកនាំចូលនៃអង្គការ WTO ដោយយោលទៅតាមវិធាន SPS ដែលអាច ត្រូវបានអនុវត្ត និង ផលវិបាកពាក់ព័ន្ធជីវសាស្ត្រនិងសេដ្ឋកិច្ចដែលអាចកើតឡើង ។

ឬ

- ការវាយតម្លៃលើសក្តានុពលនៃផលប៉ះពាល់មិនល្អ ទៅលើសុខភាពមនុស្ស ឬសត្វដែលបណ្តាល មកពីវត្តមាននៃ សារធាតុបន្ថែម មេរោគ សារធាតុពុល ឬសរីរាង្គដែលបង្កជម្ងឺនៅក្នុងម្ហូបអាហារ ភេសជ្ជៈ ឬ ចំណីសត្វ ។

ក្នុងន័យជាក់ស្តែង ការវាយតម្លៃហានិភ័យគឺជាដំណើរការនៃការប្រមូលភស្តុតាងដែលមានលក្ខណៈវិទ្យាសាស្ត្រនិងកត្តាសេដ្ឋកិច្ចពាក់ព័ន្ធ អំពីហានិភ័យពាក់ព័ន្ធក្នុងការអនុញ្ញាតឱ្យទំនិញនាំចូលណាមួយចូលក្នុងប្រទេសមួយ ។ សមាជិកប្រទេសនាំចូលអាចស្វែងរកព័ត៌មានស្តីពីបញ្ហាផ្សេងៗ ដូចជាសរីរៈចង្រៃ ឬជម្ងឺដែលអាចពាក់ព័ន្ធនឹងទំនិញដែលគេសុំច្បាប់អនុញ្ញាតិនាំចូល និង ថាតើសរីរៈចង្រៃឬជម្ងឺទាំងនេះមានវត្តមាននៅក្នុងប្រទេសនាំចេញឬទេ ។ ប្រភេទសំណួរដែលអាចសួររួមមាន: តើសរីរៈចង្រៃ ឬជម្ងឺនោះមានកើតនៅក្នុងប្រទេសអ្នកដែរឬទេ? តើសរីរៈចង្រៃ ឬជម្ងឺនោះត្រូវបាននិង កំពុងត្រូវបានគេកំចាត់ដែរឬទេ? តើសរីរៈចង្រៃ ឬជម្ងឺនោះកើតឡើងតែនៅក្នុងតំបន់ណាមួយនៃប្រទេស ឬទេ? តើនីតិវិធីដែលត្រូវបានអនុវត្តដើម្បីធានាថាផលិតផលសម្រាប់នាំចេញគ្មានសរីរៈចង្រៃ ជម្ងឺ និងមេរោគផ្សេងៗទៀតមានប្រសិទ្ធិភាពយ៉ាងណា?

---

[៣] មាត្រា ៥

▸ សំណួរនិងចម្លើយ

**រដ្ឋាភិបាលរបស់យើងគ្មានធនធានដើម្បីប្រមូលព័ត៌មានសម្រាប់ការវាយតម្លៃហានិភ័យ និង សម្រាប់ដំណើរការ កម្មវិធីឃ្លាំមើលជាបន្តឡើយ ។ តើហេតុអ្វីបានជាយើងចាំបាច់ព្រួយបារម្ភអំពីដំណើរការនេះ នៅពេលដែលយើង ចំណាយតិចជាងទៅលើការដាក់ថ្នាំបង្ហុយសម្លាប់អតិសុខុមប្រាណឬសីរីរៈចង្រៃ (fumigation) លើដំណាំ ឬទំនិញ នាំចេញរបស់យើង?**

សម្រាប់រយៈពេលវែង វិធីសាស្ត្រនេះអាចក្លាយទៅជាមិនមានលក្ខណៈសេដ្ឋកិច្ច ហើយបើសិនជាកាកសំណល់ជាតិគីមីជាបញ្ហាមួយនោះ វានឹងអាចធ្វើឱ្យអន្តរាយដល់ការធ្វើពាណិជ្ជកម្ម ។ អ្នកនឹងអាចនៅតែត្រូវផ្តល់ការបញ្ជាក់ ពីប្រសិទ្ធិភាពនៃការប្រតិបត្តិរបស់អ្នកដល់អ្នកនាំចូល ។ ការងារនេះអាចទាក់ទងដល់ការផ្តល់ព័ត៌មានអំពីសីរីរៈ ចង្រៃ និង ជម្ងឺដែលអាចមានវត្តមាន - បញ្ជីសីរីរៈចង្រៃ និង ជម្ងឺ ។ ដោយមានសមត្ថភាពផ្តល់នូវព័ត៌មាននេះ នឹងអាចជួយបង្កើនការយល់ដឹងអំពីស្ថានភាពសុខភាពនៃរបរកសិកម្មរបស់អ្នក ដែលអាចនាំទៅកាន់ការកាត់បន្ថយភាពពឹងផ្អែកលើការដាក់ថ្នាំបង្ហុយសម្លាប់អតិសុខុមប្រាណនិងសីរីរៈចង្រៃ និង វិធានដូចគ្នាផ្សេងទៀត និង មាន ការគ្រប់គ្រងហានិភ័យដែលមានលក្ខណៈសេដ្ឋកិច្ចជាង លើសីរីរៈចង្រៃ និង ជម្ងឺ ។

សមាជិកអង្គការ WTO អាចប្រកាន់យកនូវវិធាន SPS បណ្តោះអាសន្នដែលមានភ័ស្តុតាង វិទ្យាសាស្ត្រគ្រប់គ្រាន់ដើម្បីបំពេញការវាយតម្លៃហានិភ័យ ។ ក៏ប៉ុន្តែនៅក្នុងកាលៈទេសៈបែបនេះ សមាជិកអង្គការ WTO ត្រូវបានតម្រូវឱ្យស្វែងរកព័ត៌មានបន្ថែមចាំបាច់សម្រាប់ការវាយតម្លៃហានិភ័យដែលមានលក្ខណៈមិនលំអៀង នៅក្នុងរយៈពេលមួយសមស្រប ។

**ស្តង់ដារអន្តរជាតិសម្រាប់ការវាយតម្លៃហានិភ័យ**

ស្ថាប័នបងប្អូនស្រីទាំងបី (IPPC, OIE និង Codex) បានបង្កើតបច្ចេកទេសផ្សេងៗនៃការវាយតម្លៃហានិភ័យ ដែលមានបង្ហាញដូចខាងក្រោម ។ ព័ត៌មានលម្អិតបន្ថែម អាចរកឃើញនៅក្នុងគេហទំព័ររបស់ស្ថាប័នទាំងនោះ ។

IPPC បានផ្សាយស្តង់ដារបីដែលបង្កើតឡើងសម្រាប់ធ្វើការវិភាគហានិភ័យៈ

- ISPM 2. គោលការណ៍ណែនាំសម្រាប់ការវិភាគហានិភ័យសីរីរៈចង្រៃ (PRA) ។
- ISPM 11. PRA សម្រាប់សីរីរៈចង្រៃភូតគាមអនាម័យ រួមទាំងការវិភាគហានិភ័យបរិស្ថានផង ។
- ISPM 21. PRA សម្រាប់សីរីរៈចង្រៃមិនមែនភូតគាមអនាម័យ ។

អង្គការសុខភាពសត្វពិភពលោក (OIE) ធ្វើការងារការវិភាគហានិភ័យនៅក្នុង*សៀវភៅណែនាំស្តីពីការវិភាគ ហានិភ័យលើការនាំចូលសម្រាប់សត្វ និង ផលិតផលសត្វ* និង លេខកូដសម្រាប់សុខភាពសត្វរស់លើដី និង សត្វរស់ ក្នុងទឹក ។

គណៈកម្មការ Codex Allimentarius បានបោះពុម្ពផ្សាយ *គោលការណ៍ និង គោលការណ៍ណែនាំសម្រាប់ ការធ្វើការវាយតម្លៃហានិភ័យមីក្រូជីវសាស្ត្រ* និង *គោលការណ៍សម្រាប់ការវាយតម្លៃហានិភ័យលើម្ហូបអាហារ ដែលចេញពីបច្ចេកវិទ្យាជីវសាស្ត្រទំនើប*។

# ស្ថានភាពភូមិសាស្ត្រតំបន់[៤]

ចរិកលក្ខណៈនៃវិធានអនាម័យនិងភូតគាមអនាម័យរបស់តំបន់ភូមិសាស្ត្រមួយ  ពោលគឺ ទោះបីជារបស់ប្រទេសមួយទាំងមូល ជាផ្នែករបស់ប្រទេសមួយ ឬក៏ជាផ្នែកខ្លះឬទាំងមូលនៃប្រទេសមួយចំនួនក្តី ត្រូវបានលើកឡើងនៅក្នុងកិច្ចព្រមព្រៀង  SPS ថាជាស្ថានភាពភូមិសាស្ត្រតំបន់ ។ ហេតុនេះ វាអាចមានឥទ្ធិពលលើហានិភ័យដែលប៉ះពាល់ដល់ជីវិតឬសុខភាពរបស់មនុស្ស សត្វ ឬរុក្ខជាតិ ។

ក្នុងន័យនេះ កិច្ចព្រមព្រៀង SPS តម្រូវឱ្យសមាជិកអង្គការ WTO យកលំនាំវិធានអនាម័យនិងភូតគាមអនាម័យតាមស្ថានភាពតំបន់ ដែលផលិតផលមានប្រភពចេញពីតំបន់នោះ និង ផលិតផលដែលមានទិសដៅឆ្ពោះទៅកាន់តំបន់នោះ ។  ជាពិសេស សមាជិកអង្គការ WTO ត្រូវបានតម្រូវឱ្យទទួលស្គាល់ទស្សនាទានអំពីតំបន់ដែលគ្មានសីរ:ចង្រៃ/ជម្ងឺ និងតំបន់ដែលការកើតមានសីរ:ចង្រៃ/ជម្ងឺ មានកម្រិតទាប ។

សមាជិកនៃអង្គការ WTO ជាប្រទេសនាំចេញ ដែលអះអាងថា ជាទីកន្លែងដែលគ្មានសីរ:ចង្រៃ/ជម្ងឺ ឬជាទីកន្លែង ដែលការកើតមានសីរ:ចង្រៃ/ជម្ងឺមានកម្រិតទាប ត្រូវតែបង្ហាញដល់សមាជិកនៃ អង្គការ WTO ដែលជាប្រទេសនាំចូលថាទីកន្លែងនោះជា និងអាចនៅតែជាទីកន្លែងដែលគ្មាន សីរ:ចង្រៃ/ជម្ងឺ ឬ ជាទីកន្លែងដែលការកើតមានសីរ:ចង្រៃ/ជម្ងឺមានកម្រិតទាប ។

**ការបង្កើតតំបន់ដែលគ្មានសីរ:ចង្រៃ**

OIE និង IPPC បានបង្កើតស្តង់ដារសម្រាប់តំបន់ដែលគ្មានសីរ:ចង្រៃ (PFAs) ។ ស្តង់ដារដែលបោះពុម្ពផ្សាយ ដោយ  IPPC ផ្តល់នូវការណែនាំដ៏ច្បាស់លាស់មួយសម្រាប់ការបង្កើតតំបន់ដែលគ្មានសីរ:ចង្រៃលើរុក្ខជាតិ ។

- ISPM 2  និង ISPM 4  ផ្តល់នូវការណែនាំលើការអង្កេតជាក់លាក់ទាំងឡាយសម្រាប់រកឱ្យឃើញសីរ:ចង្រៃ ឬក៏ធ្វើផែនទីកំណត់ព្រំដែន និង កម្រិតនៃការរាលដាលរបស់វា ។
- ISPM 6  ផ្តល់នូវការណែនាំលើការងារអង្កេត ។
- ISPM 8  ផ្តល់ព័ត៌មានលម្អិតអំពីនីតិវិធីសម្រាប់កំណត់ស្ថានភាពរបស់សីរ:ចង្រៃនៅទីកន្លែងមួយដោយផ្អែក ទៅកំណត់ត្រាសីរ:ចង្រៃ ។

នាពេលថ្មីៗនេះ រដ្ឋាភិបាលអូស្ត្រាលីបានបោះពុម្ពផ្សាយ *គោលការណ៍ណែនាំលម្អិតសម្រាប់ការងារឃ្លាំមើល សីរ:ចង្រៃលើរុក្ខជាតិនៅតំបន់អាស៊ី និង ប៉ាស៊ីហ្វិក* (៩)

[៤] មាត្រា ៦

## តម្លាភាព[៥]

គោលការណ៍តម្លាភាពនៅក្នុងកិច្ចព្រមព្រៀង SPS តម្រូវឱ្យសមាជិកអង្គការ WTO ផ្តល់ព័ត៌មានស្តីពីវិធាន SPS និងជូនដំណឹងពីការផ្លាស់ប្តូរនៅក្នុងវិធាន SPS ។ សមាជិកអង្គការ WTO ត្រូវបានតម្រូវឱ្យបោះផ្សាយបទប្បញ្ញត្តិអនាម័យ និងភូតគាមអនាម័យ ។ ការតម្រូវឱ្យមានការជូនដំណឹង ត្រូវបានបំពេញតាមរយៈអាជ្ញាធរជូនដំណឹងថ្នាក់ជាតិមួយ ។ សមាជិកអង្គការ WTO នីមួយៗ ត្រូវចាត់ឱ្យមានចំណុចសម្របសម្រួលថ្នាក់ជាតិសម្រាប់ការងារអនាម័យនិងភូតគាមអនាម័យដែលទាក់ទិននឹងប្រទេសជាសមាជិកអង្គការ WTO ដទៃទៀត ។ អង្គភាពតែមួយអាចមានតួនាទីពីរ ទាំងការជូនដំណឹងនិងសាកសួរដំណឹង ។

សៀវភៅណែនាំប្រតិបត្តិ *តើត្រូវអនុវត្តមាត្រាតម្លាភាពនៃកិច្ចព្រមព្រៀង SPS យ៉ាងដូចម្តេច* អាចចម្លងបានពីគេហទំព័រវិធាន SPS របស់អង្គការ WTO [៣] ។



ជំនាញធ្វើរោគវិនិច្ឆ័យ (diagnosis) សរីរៈចង្រៃនិងជម្ងឺលើរុក្ខជាតិ មានសារៈសំខាន់ណាស់សម្រាប់ សមាជិកអង្គការ WTO នៅក្នុងការអនុវត្តកិច្ចព្រមព្រៀង SPS ។

---

[៥] មាត្រា ៧

# ជំនួយបច្ចេកទេស និង ប្រព្រឹត្តិកម្មពិសេស

អង្គការ WTO ទទួលស្គាល់ថា សមត្ថភាពបច្ចេកទេសក្នុងការអនុវត្តន៍កិច្ចព្រមព្រៀង SPS គឺមានលក្ខណៈខុសគ្នារវាងសមាជិកនីមួយៗនៃអង្គការ WTO ។ ជាពិសេស សមាជិកជាប្រទេសកំពុងអភិវឌ្ឍ អាចយល់ថា ការអនុវត្តជាការងារដែលត្រូវពុះពារ ដោយសារកង្វះខាតធនធាន រួមទាំងជំនាញឯកទេសដែលមានកម្រិតផង ។

ដើម្បីជួយក្នុងការជំនះបញ្ហានេះ យន្តការមួយចំនួនបានត្រូវគេដាក់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀង SPS ។

សមាជិកអង្គការ WTO យល់ព្រមជួយសម្របសម្រួលក្នុងការផ្តល់ជំនួយបច្ចេកទេសជូនសមាជិកដទៃទៀត ជាពិសេសប្រទេសកំពុងអភិវឌ្ឍ ក្នុងលក្ខណៈទ្វេភាគី ឬក៏តាមរយៈអង្គការអន្តរជាតិ ដូចជាស្ថាប័នបងប្អូនស្រីទាំងបី (IPPC, IOE និង Codex) ជាដើម ។ ប្រភេទនៃជំនួយបច្ចេកទេស និងរបៀបផ្តល់ត្រូវបានកំណត់ក្នុងលក្ខណៈទូលំទូលាយ[៦] ។

កិច្ចព្រមព្រៀង SPS ក៏ចែងផងដែរពីប្រព្រឹត្តិកម្មពិសេស និង ផ្សេងៗគ្នា[៧] ។ ឧទាហរណ៍ ក្នុងការអនុវត្តវិធាន SPS សមាជិកអង្គការ WTO ត្រូវបានកំណត់ឱ្យគិតគូរពីតម្រូវការពិសេសរបស់សមាជិកជាប្រទេសកំពុងអភិវឌ្ឍ ជាពិសេសប្រទេសជាសមាជិកដែលមានការអភិវឌ្ឍន៍តិចជាងគេ ។

ប្រទេសកំពុងអភិវឌ្ឍជាច្រើនដែលជាសមាជិកអង្គការ WTO បានទទួលផលប្រយោជន៍ ដោយផ្អែកវិធាន SPS របស់គេលើស្តង់ដារអន្តរជាតិ គោលការណ៍ណែនាំ និងអនុសាសន៍មានស្រាប់ ដែលចេញដោយស្ថាប័នបងប្អូនស្រីទាំងបី (IPPC, IOE និង Codex) ។

# តើនរណាជាអ្នកទទួលផលប្រយោជន៍?

កិច្ចព្រមព្រៀង SPS គាំទ្ររបៀបវារៈរបស់អង្គការ WTO ដើម្បីលើកស្ទួយការធ្វើពាណិជ្ជកម្មសេរីជាសកល និងធ្វើឱ្យសម្រេចបាននូវផលប្រយោជន៍ដែលផ្តល់ជូនសមាជិកអង្គការ WTO ទាំងអស់ ទាំងប្រទេសអភិវឌ្ឍ និង ប្រទេសកំពុងអភិវឌ្ឍ ។

កិច្ចព្រមព្រៀង SPS ទទួលស្គាល់សិទ្ធិសមាជិកអង្គការ WTO ក្នុងការការពារជីវិត ឬ សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ប្រសិនបើលក្ខខណ្ឌមួយចំនួនត្រូវបានបំពេញ ។ លក្ខខណ្ឌគន្លឹះគឺថាវិធាន SPS ត្រូវតែមានមូលដ្ឋានវិទ្យាសាស្ត្រ មិនត្រូវមានលក្ខណៈរឹតត្បិតការធ្វើពាណិជ្ជកម្មឱ្យលើសពីតម្រូវការ មិនត្រូវមានការរើសអើងទាំងបំពាន ឬដោយមិនសមហេតុផល ហើយមិនត្រូវគឺជាការក្លែងបន្លំរឹតត្បិតលើការធ្វើពាណិជ្ជកម្មអន្តរជាតិ ។ គោលដៅរួម គឺពាណិជ្ជកម្មដែលមានលក្ខណៈសេរី និង ដំណើរការល្អ ។

---

[៦] មាត្រា ៩

[៧] មាត្រា ១០

ប្រទេសនាំចេញ និង ប្រទេសនាំចូលទំនិញកសិកម្មជាសមាជិក WTO ទាំងអស់ទទួលផលប្រយោជន៍ពីវិធានដែលបង្កើតដោយកិច្ចព្រមព្រៀង SPS ។ ជាចំណែកនៃប្រព័ន្ធពាណិជ្ជកម្មសកលរបស់អង្គការ WTO ដែលផ្អែកលើច្បាប់ទម្លាប់ជាធំនោះ កិច្ចព្រមព្រៀង SPS ត្រូវបានអនុវត្តដើម្បីធានាឱ្យបានថា ពាណិជ្ជកម្មកសិកម្មដំណើរការក្នុងលក្ខណៈរលូន អាចព្យាករណ៍បាន និង ដោយសេរី តាមដែលអាចធ្វើទៅបាន ។ ជាពិសេស កិច្ចព្រមព្រៀង SPS ផ្តល់នូវមូលដ្ឋានដែលគ្មានលំអៀងក្នុងការវាយតម្លៃវិធាន SPS ណាដែលរឹតត្បិតការធ្វើពាណិជ្ជកម្មដោយមិនសមហេតុសមផល ។ លើសពីនេះទៀត អ្នកប្រើប្រាស់ទទួលផលប្រយោជន៍ពីភាពអាចរកបាននូវម្ហូបអាហារ និង ទំនិញកសិកម្មដែលមានសុវត្ថិភាព និងមានតម្លៃប្រកួតប្រជែង ។

ប្រទេសកំពុងអភិវឌ្ឍទទួលផលប្រយោជន៍ពីជំនួយបច្ចេកទេសដែលមាន ដើម្បីកែលំអប្រព័ន្ធចត្តាឡីស័ក និង សុវត្ថិភាពម្ហូបអាហារ ដោយរួមបញ្ចូលទាំងសមត្ថភាពដែលត្រូវបានបង្កើនក្នុងការធ្វើការព្យាករណ៍ ការវិភាគ អធិការកិច្ច ការចេញវិញ្ញាបនបត្រ ការគ្រប់គ្រងព័ត៌មាន និង ការធ្វើរបាយការណ៍ ។ សមត្ថភាពអនាម័យ និងភូតគាមអនាម័យដែលត្រូវបានលើកកំពស់នេះ នឹងអាចបើកទូលាយទីផ្សារអន្តរជាតិបន្ថែមទៀតសម្រាប់អ្នកនាំចេញ នៅក្នុងប្រទេសកំពុងអភិវឌ្ឍទាំងនេះ ។ លើសពីនេះទៀត វានឹងជួយគាំទ្រដល់ការគ្រប់គ្រងរបរកសិកម្ម ផ្តល់ផលប្រយោជន៍ជាទូទៅដល់ផលិតករ និង អ្នកប្រើប្រាស់ក្នុងស្រុក ។



កិច្ចព្រមព្រៀង SPS គាំទ្រការផ្តល់ជំនួយបច្ចេកទេសដល់ប្រទេសកំពុងអភិវឌ្ឍ ។

# តើអ្នកអាចស្វែងយល់បន្ថែមពីទីណាខ្លះ....

[1] អត្ថបទទាំងមូលស្តីពីកិច្ចព្រមព្រៀង SPS មាននៅ:
<http://www.wto.org/English/tratop_e/sps_e/spsagr_e.htm>

[2] ការបោះពុម្ពផ្សាយនៅក្នុងកិច្ចព្រមព្រៀង WTO ជាភាគដែលមានផ្សាយពីវិធាន SPS ។ វាពន្យល់ពីកិច្ចព្រមព្រៀងដោយរួមបញ្ចូលទាំងភាពខុសគ្នារវាងវិធាន កិច្ចព្រមព្រៀង SPS និង របាំងបច្ចេកទេស ក្នុងការធ្វើពាណិជ្ជកម្ម (TBT) និង ឆ្លើយតបចំពោះសំណួរដែលសួរជាញឹកញាប់ ។ សូមរកមើលនៅ:
<http://www.wto.org/english/res_e/booksp_e/agrmntseries4_sps_e.pdf>

[3] ច្រកចូលគេហទំព័រ វិធាន SPS របស់ WTO បើកបង្ហាញឱ្យឃើញព័ត៌មានស្តីពីកិច្ចព្រមព្រៀង និង ការអភិវឌ្ឍន៍និងសកម្មភាព SPS ទូទាំងពិភពលោក:
<http://www.wto.org/english/tratop_e/sps_e/sps_e.htm>

[4] ព័ត៌មានស្តីពីមុខងារ និងសកម្មភាពរបស់គណៈកម្មាធិការ SPS អាចរកឃើញនៅ:
<http://www.wto.org/english/tratop_e/sps_e/sps_agreement_cbt_e/c4s1p1_e.htm>

[5] សុវត្ថិភាពម្ហូបអាហារ និង ស្តង់ដារសម្រាប់សុខភាពកសិកម្ម: បញ្ហាប្រឈម និង កាលានុវត្តភាព សម្រាប់ប្រទេសនាំចេញដែលជាប្រទេសកំពុងអភិវឌ្ឍ របាយការណ៍ធនាគារពិភពលោកលេខ 31207 អាចរកឃើញ នៅ <http://www.worldbank.org/trade/standards> ហើយសូមស្វែងរក “food safety”

[6] ច្រកទ្វារភូតគាមអនាម័យអន្តរជាតិ (IPP) នៅ <http://www.ippc.int> គឺជាវេទិកា សម្រាប់ របាយការណ៍ និងផ្លាស់ប្តូរព័ត៌មានដោយរដ្ឋាភិបាល ។

[7] ព័ត៌មានស្តីពីសកម្មភាពរបស់អង្គការសុខភាពសត្វពិភពលោកអាចរកឃើញនៅ:
<http://www.oie.int>

[8] អស័យដ្ឋានគេហទំព័ររបស់គណៈកម្មការ Codex Alimentarius គឺ:
<http://www.codexalimentarius.net>

[9] នៅពេលថ្មីៗនេះរដ្ឋាភិបាលអូស្ត្រាលីបោះពុម្ពផ្សាយលម្អិត “គោលការណ៍ណែនាំសម្រាប់ការ ឃ្លាំមើលសិរីរៈចង្រៃលើរុក្ខជាតិនៅអាស៊ី និង ប៉ាស៊ីហ្វិក” ។ ឯកសារនេះអាចរកឃើញនៅ:
<http://www.aciar.gov.au/web.nsf/doc/ACIA-6HZ3TK>

## អស័យដ្ឋានប្រៃសណីយសម្រាប់ស្ថាប័នបងប្អូនស្រីទាំងបី...


**IPPC Secretariat**

Plant Production and Protection Division
Food and Agriculture Organization of the United Nations
Viale delle Terme di Caracalla
00100 Rome, Italy

**World Organisation for Animal Health**

12, rue de Prony
75017 Paris, France

**Codex Alimentarius Commission**

Food and Agriculture Organization of the United Nations
Viale delle Terme di Caracalla
00100 Rome, Italy


Production by Clarus Design